# កិច្ចព្រមព្រៀងអាស៊ានស្តីពី
# ការគ្រប់គ្រងគ្រោះមហន្តរាយ និង
# ការឆ្លើយតបសង្គ្រោះបន្ទាន់



សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ ។ រដ្ឋជាសមាជិករួមមាន : ប្រ៊ុយណេ ដារូសសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិតេយ្យ ប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។ លេខាធិការដ្ឋានអាស៊ាន មានទីស្នាក់ការប្រចាំនៅទីក្រុង ហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ។

សម្រាប់ព័ត៏មានបន្ថែម សូមទំនាក់ទំនង :
និយកដ្ឋានសង្គមស៊ីវិល និងទំនាក់ទំនងសាធារណ
លេខាធិការដ្ឋានអាស៊ាន
៧០A, ចាឡេន, ស៊ីសឹងហ្គាម៉ាហ្គារ៉ាចា
ហ្សាកាតា ១២១១០
ប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ : (៦២.២១) ៧២៤-៣៣៧២, ៧២៦-២៩៩១
ទូរសារ : (៦២.២១) ៧៣៩-៨២៣៤, ៧២៤-៣៥០៤
សារអេឡិចត្រូនិច : public.div@asean.org

ព័ត៏មានទូទៅស្តីពីសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ត្រូវបានបង្ហាញ
នៅក្នុងគេហទំព័រសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ : www.asean.org

ឯកសារដែលបានបោះពុម្ពផ្សាយ

កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់
លេខាធិការដ្ឋានអាស៊ាន
ហ្សាកាតា : លេខាធិការដ្ឋានអាស៊ាន ខែកុម្ភៈ ឆ្នាំ២០១០

បោះពុម្ព ២ពណ៌ ចំនួន ២៤ទំព័រ ទំហំ ១៥ x ២១ ស.ម

ចំណាត់ថ្នាក់លេខ : ៣៦៣.៣៤៨០៦៨
ចំណងជើង : ១. កិច្ចព្រមព្រៀងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
២. កិច្ចព្រមព្រៀងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ស្តីពីការគ្រប់គ្រងការជួយសង្គ្រោះបន្ទាន់

លេខសៀវភៅជាស្តង់ដារ : ៩៧៩-៣៤៩៦-២៤-x

បោះពុម្ពលើកទី ១ : ខែកក្កដា ឆ្នាំ២០០៦
បោះពុម្ពឡើងវិញលើកទី ១ : ខែមករា ឆ្នាំ២០០៧
បោះពុម្ពឡើងវិញលើកទី ២ : ខែឧសភា ឆ្នាំ២០០៩
បោះពុម្ពឡើងវិញលើកទី ៣ : ខែធ្នូ ឆ្នាំ២០០៩
បោះពុម្ពឡើងវិញលើកទី ៤ : ខែកុម្ភៈ ឆ្នាំ២០១០
បោះពុម្ពនៅប្រទេសឥណ្ឌូនេស៊ី

បោះពុម្ពលើកទី ១ ជាភាសាខ្មែរ ខែមិថុនា ឆ្នាំ២០១១ ដោយក្រុមសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (A.P.G)

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

រាល់អត្ថបទរបស់សៀវភៅនេះ អាចដកស្រង់សំរាប់ការបោះពុម្ពឡើងវិញតាមអត្ថន័យត្រឹមត្រូវ និងសមស្របតាមច្បាប់ដើម

រក្សាសិទ្ធិដោយលេខាធិការដ្ឋានអាស៊ាន ២០០៩

# កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់

# មាតិកា


ផ្នែកទី I បទបញ្ញត្តិទូទៅ

ប្រការទី ១. ការប្រើប្រាស់ស័ព្ទ ៣
ប្រការទី ២. គោលដៅ ៤
ប្រការទី ៣. គោលការណ៍ ៥
ប្រការទី ៤. កាតព្វកិច្ចទូទៅ ៥

ផ្នែកទី II ការរកអត្តសញ្ញាណ ការប៉ាន់ប្រមាណ និងការតាមដានត្រួតពិនិត្យគ្រោះភ័យនៃគ្រោះមហន្តរាយ

ប្រការទី ៥. ការរកអត្តសញ្ញាណ និងការតាមដានត្រួតពិនិត្យគ្រោះភ័យ ៦

ផ្នែកទី III ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់គ្រោះមហន្តរាយ

ប្រការទី ៦. ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់គ្រោះមហន្តរាយ ៧

ផ្នែកទី IV ការត្រៀមរៀបចំគ្រោះមហន្តរាយ

ប្រការទី ៧. ការប្រកាសប្រាប់អោយដឹងជាមុននូវគ្រោះមហន្តរាយ ៧
ប្រការទី ៨. ការត្រៀមរៀបចំ ៨
ប្រការទី ៩. ការរៀបចំបំរុងអាស៊ានសំរាប់ការជួយសង្គ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ៩

ផ្នែកទី V ការឆ្លើយតបសង្គ្រោះបន្ទាន់

ប្រការទី ១០. ការឆ្លើយសង្គ្រោះបន្ទាន់ថ្នាក់ជាតិ ៩
ប្រការទី ១១. ការឆ្លើយតបសង្គ្រោះបន្ទាន់រួមគ្នាតាមរយៈការផ្តល់ជំនួយ ៩
ប្រការទី ១២. ការដឹកនាំ និងការត្រួតពិនិត្យជំនួយ ១០
ប្រការទី ១៣. ការគោរពច្បាប់ និងបទប្បញ្ញត្តិជាតិ ១១
ប្រការទី ១៤. ការលើកលែងពន្ធ និងមូលដ្ឋានសំភារៈក្នុងក្របខ័ណ្ឌនៃការផ្តល់ជំនួយ ១១
ប្រការទី ១៥. អត្តសញ្ញាណកម្ម ១២
ប្រការទី ១៦. ការឆ្លងកាត់របស់បុគ្គលិក បរិក្ខារ មូលដ្ឋានសំភារៈ និងសំភារៈផ្សេងៗក្នុងក្របខ័ណ្ឌនៃការផ្តល់ជំនួយ ១២

ផ្នែកទី VI ការស្តារឡើងវិញ

ប្រការទី ១៧. ការស្តារឡើងវិញ ១៣

ផ្នែកទី VII កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការស្រាវជ្រាវវិទ្យាសាស្ត្រ
ប្រការទី ១៨. កិច្ចសហប្រតិបត្តិការបច្ចេកទេស ___ ១៣
ប្រការទី ១៩. ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស ___ ១៤

ផ្នែកទី VIII មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជំនួយមនុស្សធម៌
ប្រការទី ២០. មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជំនួយមនុស្សធម៌ ___ ១៤

ផ្នែកទី IX ការរៀបចំស្ថាប័ន
ប្រការទី ២១. សន្និសីទនៃភាគីទាំងឡាយ ___ ១៥
ប្រការទី ២២. មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ និងអាជ្ញាធរមានសមត្ថកិច្ច ___ ១៥
ប្រការទី ២៣. លេខាធិការដ្ឋាន ___ ១៦
ប្រការទី ២៤. ការរៀបចំហិរញ្ញវត្ថុ ___ ១៦

ផ្នែកទី X និតិវិធី
ប្រការទី ២៥. ពិធីសារ ___ ១៧
ប្រការទី ២៦. វិសោធនកម្មចំពោះកិច្ចព្រមព្រៀង ___ ១៧
ប្រការទី ២៧. ការប្រកាន់យក និងវិសោធនកម្មនៃឧបសម្ព័ន្ធទាំងឡាយ ___ ១៨
ប្រការទី ២៨. ក្រិត្យក្រមនៃនិតិវិធី និងក្រិត្យក្រមហិរញ្ញវត្ថុ ___ ១៨
ប្រការទី ២៩. របាយការណ៍ ___ ១៩
ប្រការទី ៣០. ភាពទំនាក់ទំនងជាមួយឧបករណ៍ដទៃទៀត ___ ១៩
ប្រការទី ៣១. ដំណោះស្រាយជំលោះ ___ ១៩

ផ្នែកទី XI អវសានបទ
ប្រការទី ៣២. សច្ចាប័ន ការទទួលយក ការយល់ព្រម និងការទទួលបាន ___ ១៩
ប្រការទី ៣៣. ការចូលជាធរមាន ___ ១៩
ប្រការទី ៣៤. ការបំរុង ___ ២០
ប្រការទី ៣៥. អ្នកតំកល់ឯកសារ ___ ២០
ប្រការទី ៣៦. អត្ថបទជាក់ស្តែង ___ ២០

ឧបសម្ព័ន្ធ ល័ក្ខខ័ណ្ឌការងាររបស់មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជំនួយមនុស្សធម៌ (មជ្ឈមណ្ឌល AHA) ___ ២៣

# កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់

## ភាគីទាំងឡាយចំពោះកិច្ចព្រមព្រៀងនេះ

- ដោយអះអាងជាថ្មីពីការប្តេជ្ញាអនុវត្តន៍ចំពោះគោលដៅ និងគោលបំណងរបស់សមាគមប្រជាជាតិអាគ្នេយ៍ (អាស៊ាន) ដូចបានដាក់ចេញនៅក្នុងសេចក្តីថ្លែងការណ៍ ទីក្រុងបាងកក នាថ្ងៃទី ៨ ខែសីហា ឆ្នាំ១៩៦៧ ជាពិសេស លើកទឹកចិត្តដល់កិច្ចសហប្រត្តិបត្តិការថ្នាក់តំបន់នៅអាស៊ីភាគអាគ្នេយ៍ ក្នុងស្មារតីសមភាព និងភាពជាដៃគូប្រទេសរួមចំណែកឆ្ពោះទៅរកសន្តិភាព វឌ្ឍនភាព និងវិបុលភាពនៅក្នុងតំបន់។
- ដោយអះអាងឡើងវិញផងដែរ អំពីគោលដៅ និងគោលការណ៍នៃសេចក្តីថ្លែងការណ៍អាស៊ានកុងគ័រដ នាថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ ក្នុងចំណោមសេចក្តីថ្លែងការណ៍ដទៃទៀតដែលបានបញ្ជាក់ថាជាមួយនឹងសមត្ថភាពរបស់ខ្លួន ប្រទេសជាសមាជិកទាំងឡាយ នឹងផ្តល់ជំនួយសង្គ្រោះជូនប្រទេសជាសមាជិកដែលជួបប្រទះភ័យន្តរាយ និងសេចក្តីថ្លែងការណ៍អាស៊ានកុងគ័រដ នាថ្ងៃទី ៧ ខែតុលា ឆ្នាំ២០០៣ ដែលអាស៊ាននឹងបង្កើនកិច្ចសហប្រត្តិបត្តិការតាមរយៈសហគមន៍ សង្គម វប្បធម៌ អាស៊ាន ក្នុងការឆ្លើយតបចំពោះបញ្ហាទាំងឡាយរួមផ្សំជាមួយបញ្ហាដទៃទៀត មានដូចជាការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងតំបន់ដើម្បីបង្កើនសមត្ថភាពប្រទេសរបស់ខ្លួនធ្វើការសំរេចចិត្តដោយពេញលេញនូវសក្តានុពលភាពអភិវឌ្ឍន៍របស់ខ្លួនសំរាប់លើកកំពស់ស្មារតីអាស៊ានជួយគ្នាទៅវិញទៅមក។
- ដោយអះអាងជាថ្មីឡើងវិញផងដែរ ចំពោះប្រការបទប្បញ្ញត្តិនៃកម្មវិធីសកម្មភាពក្រុងវៀងច័ន្ទ ឆ្នាំ ២០០៤-២០១០ ដើម្បីបន្តអនុវត្តន៍ សមាហារណកម្មពេញលេញរបស់អាស៊ានឆ្ពោះទៅកាន់ការសំរេចចិត្តនៃសហគមន៍អាស៊ានបើកចំហរ មានថាមភាព និងស្តារឡើងវិញបានមុនឆ្នាំ ២០២០ ដូចចក្ខុវិស័យក្នុងសេចក្តីថ្លែងការណ៍នៃអាស៊ានកុងគ័រដ តាមរយៈផែនការណ៍សកម្មភាពរបស់សហគមន៍សន្តិសុខអាស៊ាន (ASC) សហគមន៍ សង្គមវប្បធម៌អាស៊ាន (ASCC) និងអនុសាសន៍របស់ក្រុមការងារកំរិតខ្ពស់ ស្តីពីសមាហារណកម្មសេដ្ឋកិច្ច។
- ដោយយោងលើសេចក្តីថ្លែងការណ៍ ស្តីពីការផ្តល់ជំនួយសង្គ្រោះបន្ទាន់ស្តារឡើងវិញកសាងឡើងវិញ និងការត្រៀមបង្ការទប់ក្រោយពេលគ្រោះមហន្តរាយរញ្ជួយផែនដី និងរលកស៊ូណាមិ នាថ្ងៃទី២៦ ឆ្នាំ២០០៤ ដែលអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន ពិសេសក្រោយពេលគ្រោះរញ្ជួយផែនដី និងរលកយក្សស៊ូណាមិ នាថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០៥។
- ដោយយោងទៅលើសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការជួយគ្នាទៅវិញទៅមកចំពោះគ្រោះមហន្តរាយដោយធម្មជាតិ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៦ ដែលអំពាវនាវអោយប្រទេស

ជាសាមាជិករួមសហប្រត្តិបត្តិការក្នុងការកែលំអសមត្ថភាព គ្រប់គ្រងគ្រោះមហន្តរាយ និងករណីមហន្តរាយធំធេង ដើម្បីផ្តល់ជំនួយទៅតាមតំរូវការនៅពេលមានសំណើសុំពីប្រទេសជាសមាជិករងគ្រោះ ។

- ដោយយោងតាមកិច្ចព្រមព្រៀងអាស៊ានស្តីពីផ្សែងពុលអ័ព្ទឆ្លងដែន ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ដែលផ្តល់នូវគំរោងសកម្មភាពសហប្រត្តិបត្តិការលើការត្រៀមបង្ការតាមដានត្រួតពិនិត្យ កាត់បន្ថយគ្រោះថ្នាក់និងឆ្លើយតបចំពោះផ្សែងពុលអ័ព្ទឆ្លងដែននៅក្នុងបរិបទទាំងមូលនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។
- ដោយយោងទៅលើកិច្ចព្រមព្រៀងអាស៊ាន សំរាប់បង្កលក្ខណៈងាយស្រួលដល់ការរុករកយន្តហោះដែលជួបមហន្តរាយ និងសង្គ្រោះអ្នកដែលនៅរស់រានមានជីវិតពីគ្រោះថ្នាក់ដោយយន្តហោះ ចុះថ្ងៃទី ១៤ ខែមេសា ឆ្នាំ១៩៧២ និងកិច្ចព្រមព្រៀងអាស៊ានបន្តអោយងាយស្រួលដល់ការរុករកនាវាជួបមហន្តរាយ និងសង្គ្រោះអ្នកនៅរស់រានមានជីវិតនៃគ្រោះថ្នាក់នាវាចរ ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៨៧៥ ដែលអំពាវនាវដោយប្រទេសសមាជិកអាស៊ានជួយផ្តល់ដែនដីរបស់ខ្លួន និងធានាដល់ការចូល និងការសរបសំរួលរបស់បុគ្គលជំនាញត្រូវការសំរាប់ប្រត្តិបត្តិការចូលរុករក និងសង្គ្រោះ ។
- ដោយយោងទៅលើកិច្ចព្រមព្រៀងស្តីពីការបំរុងទុកសន្តិសុខស្បៀងអាស៊ាន ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៧៩ ដែលអំពាវនាវអោយមានការខិតខំប្រឹងប្រែងអោយមានប្រសិទ្ធភាពនិងរួមផ្សំគ្នាដើម្បីរៀបចំនូវការបំរុងទុកសន្តិសុខស្បៀងក្នុងចំណោមប្រទេសជាសមាជិកសំរាប់ពិនិត្យដល់ការស្តារប្រក្រតីភាព និងសាមគ្គីភាពថ្នាក់ជាតិនៅថ្នាក់តំបន់ដោយរៀបចំឡើងនូវឃ្លាំងបំរុងទុកអង្ករសង្គ្រោះបន្ទាន់អាស៊ាន ដើម្បីគោលបំណងដោះស្រាយតំរូវការនៅគ្រាអាសន្ន ។
- ដោយយោងទៅលើសេចក្តីសំរេច មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៩/២៧៩ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៥ សំរាប់ជំនួយសង្គ្រោះបន្ទាន់ ការស្តារឡើងវិញ ការកសាងឡើងវិញ និងការត្រៀមបង្ការនៅក្រោយពេលគ្រោះមហន្តរាយរលកយក្សស៊ូណាមិនៅមហាសមុទ្រឥណ្ឌា សេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាតិ លេខ ៤៦/១៨២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩១ ដើម្បីអនុម័តវិធីសមាហារណកម្មសំរាប់ការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ទិដ្ឋភាពទាំងអស់ និងសំរាប់ផ្តួចផ្តើមគំនិតនូវដំណើរការមួយឆ្ពោះទៅរកវប្បធម៌សាកលនៃការត្រៀមបង្ការនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៧/៥៧៨/ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០២ ដោយលើកទឹកចិត្តដល់ការពង្រឹងកិច្ចសហប្រត្តិបត្តិការក្នុងចំណោមរដ្ឋនៅថ្នាក់តំបន់ និងថ្នាក់អនុតំបន់ធ្វើការត្រៀមរៀបចំ និងការឆ្លើយតបគ្រោះមហន្តរាយដោយយកចិត្តទុកដាក់ទៅលើការកសាងសមត្ថភាពនៅគ្រប់កំរិតទាំងអស់ ។
- ដោយយោងទៅលើសេចក្តីថ្លែងការណ៍ហ៊ីយោហ្គោ និងគំរោងសកម្មភាពហ៊ីយោហ្គោ ដែលបានដាក់ចេញដោយសន្និសីទពិភពលោក ស្តីពីការកាត់បន្ថយគ្រោះមហន្តរាយនៅខែមករា

ឆ្នាំ២០០៥ ដែលយកចិត្តទុកដាក់ទៅលើតំរូវការពង្រាង និងអភិវឌ្ឍវិធីសំរបសំរួលថ្នាក់តំបន់នៅពេលណាចាំបាច់ ព្រមទាំងបន្ថែម រឺលើកកំពស់គោលនយោបាយថ្នាក់តំបន់ យន្តការប្រត្តិបត្តិ ផែនការប្រព័ន្ធទាក់ទង ដើម្បីរៀបចំវិធានការដល់ការឆ្លើយតបមហន្តរាយ បានរហ័ស និងប្រសិទ្ធភាពក្នុងស្ថានភាពដែលហួសពីសមត្ថភាពដោះស្រាយថ្នាក់ជាតិ ។

- ដោយកំណត់ថានឹងផ្តល់ចំណែញដល់កម្មវិធីប្រចាំតំបន់អាស៊ាន ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយ ២០០៤-២០១០ ដែលអំពាវនាវដល់ការអនុវត្តនីនូវសំណើគំរោងផ្សេងៗ និងសំណើគំរោងអាទិភាពទាំងឡាយរួមមានការរៀបចំឡើងនូវផែនការសកម្មភាពឆ្លើយតបអាស៊ាន
- ដោយចាប់អារម្មណ៏ទៅលើការកើនឡើងនូវចំនួនដង និងក៏រិតនៃគ្រោះមហន្តរាយក្នុងតំបន់អាស៊ាន ព្រមទាំងផលប៉ះពាល់ទាំងរយៈពេលខ្លី និងរយៈពេលវែង ។
- ដោយពិនិត្យឃើញថាមធ្យោបាយជាសារវន្តមួយក្នុងការសំរេចនូវសកម្មភាពជាសមូហភាពបែបនេះគឺជាការអនុវត្តន៏ប្រកបដោយប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងនេះ សន្និដ្ឋានចុងក្រោយ និងបានយល់ព្រមដូចតទៅនេះ :

## ផ្នែកទី I: បទបញ្ញត្តិទូទៅ

### ប្រការទី ១. ការប្រើប្រាស់ស័ព្ទ

សំរាប់គោលបំណង នៃកិច្ចព្រមព្រៀងនេះ :

១. "ភាគីជួយ" មានន័យថារដ្ឋមួយ អង្គការអន្តរជាតិមួយ និងភាគីដទៃទៀតរឺបុគ្គលម្នាក់ដែលផ្តល់ និង/ឬឧបត្ថមជំនួយដល់ភាគីទទួលជំនួយ ឬភាគីស្នើសុំណាមួយនៅក្នុងព្រឹត្តិការណ៏នៃការសង្គ្រោះបន្ទាន់ចំពោះគ្រោះមហន្តរាយ ។

២. "អជ្ញាធរមានសមត្ថកិច្ច" អង្គភាពមួយ ឬច្រើនជាងនេះត្រូវការចាត់តាំង និងអនុញ្ញាតដោយភាគីនីមួយៗ ដើម្បីធ្វើសកម្មភាពក្នុងនាមរបស់ខ្លួនក្នុងការអនុវត្តន៏កិច្ចព្រមព្រៀងនេះ ។

៣. "គ្រោះមហន្តរាយ " មានន័យថាការកាត់ផ្តាច់ធ្ងន់ធ្ងរនូវដំណើរការប្រព្រឹត្តទៅនៃសហគមន៏ ឬសង្គមមួយបង្កអោយមានការបាត់បងធំធេងនូវជីវិតមនុស្ស សំភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ។

៤. "ការគ្រប់គ្រងមហន្តរាយ " មានន័យថាសកម្មភាពមួយចំនួនមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយសំដៅថែរក្សា ការត្រួតពិនិត្យ, តាមដានពីគ្រោះមហន្តរាយ និងផ្តល់គំរោងសកម្មភាពសំរាប់ជួយមនុស្សដែលស្ថិតក្នុងគ្រោះភ័យ និង/ឬសហគមន៏ណាមួយដើម្បីបញ្ចៀសកាត់បន្ថយជាអប្បរមា ឬស្តារប្រក្រតីភាពឡើងវិញពីផលប៉ះពាល់នៃគ្រោះមហន្តរាយ ។

៥. "គ្រោះភ័យនៃគ្រោះមហន្តរាយ " មានន័យថា ប្រហាក់ប្រហែលនៃផលវិបាកខូតខាត

ឬការបាត់បង់រំពឹងទុកក្នុងក្របខ័ណ្ឌមរណភាព ការរងរបួស ទ្រព្យសម្បត្តិ ជីវភាព រស់នៅសកម្មភាពខាងសេដ្ឋកិច្ច ឬខូចខាតដល់បរិស្ថានបណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ ឬដោយមនុស្សបង្ក និងស្ថានភាពងាយរងគ្រោះ ។

៦. "ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ " មានន័យថា ក្របខ័ណ្ឌទស្សនៈទានមួយនៃកត្តាទាំងឡាយ ដែលចាត់ទុកថាជាលទ្ធភាពកាត់បន្ថយអោយទៅជាអប្បរមាចំពោះភាពងាយរងគ្រោះ និងគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងសង្គមទាំងមូល ដើម្បីបញ្ចៀសតាមរយៈការត្រៀមរៀបចំ និងការកាត់បន្ថយគ្រោះថ្នាក់នូវផលប៉ះពាល់អវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់នៅក្នុងបរិបទនៃការអភិវឌ្ឍន៍ជានិរន្តរភាព ។

៧. "ការសង្គ្រោះបន្ទាន់នូវគ្រោះថ្នាក់មហន្តរាយ " មានន័យជាស្ថានភាពកន្លែងមួយដែលភាគីអះអាងថាពុំមានលទ្ធផលដោះស្រាយចំពោះគ្រោះមហន្តរាយ ។

៨. "មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ " មានន័យថាជាអត្ថិភាពមួយចាត់តាំង និងអនុញ្ញាតិដោយភាគីដើម្បីទទួល និងបញ្ជូនពតិមានស្របតាមបទប្បញ្ញតិនៃកិច្ចព្រមព្រៀង ។

៩. "មុខសញ្ញាគ្រោះថ្នាក់ " មានន័យថាជាព្រឹត្តិការណ៍មួយ បាតុភូតមួយ រឺសកម្មភាពរបស់មនុស្សដែលសក្តានុពលអាចធ្វើអោយខូចខាតជារូបវន្តខ្លាំងក្លារួមមានការបង្កអោយមានការបាត់បង់អាយុជីវិត រឺរបួសស្នាម ការខូចខាតទ្រព្យសម្បត្តិ ការអាក់ដំណើរការសង្គម និងសេដ្ឋកិច្ច រឺការខូចបង់នៃបរិស្ថាន ។

១០. "រដ្ឋជាសមាជិក " មានន័យថាប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ។

១១. "ភាគី " មានន័យថាប្រទេសជាសមាជិកមួយដែលបានយល់ព្រមក្នុងបំណងភ្ជាប់នៃកិច្ចព្រមព្រៀងនេះ ហើយដែលត្រូវចាប់បង្ខំដោយកិច្ចព្រមព្រៀង ។

១២. "ភាគីទទួល " មានន័យថាភាគីនីមួយៗដែលទទួលយកជំនួយផ្តល់ដល់អង្គភាពជួយមួយ ឬច្រើននៅក្នុងហេតុការណ៍នៃការជួយសង្គ្រោះបន្ទាន់ចំពោះគ្រោះមហន្តរាយ ។

១៣. "ភាគីស្នើសុំ " មានន័យថាភាគីមួយដែលស្នើសុំជំនួយអំពីភាគីមួយ ឬច្រើនបំផុតនៅក្នុងហេតុការណ៍នៃការសង្គ្រោះបន្ទាន់ចំពោះគ្រោះមហន្តរាយ ។

## ប្រការទី ២. គោលដៅ

គោលដៅនៃកិច្ចព្រមព្រៀងនេះ គឺផ្តល់ជូននូវយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីសំរេចការកាត់បន្ថយជាសំខាន់នៃការបាត់បង់អាយុជីវិតមនុស្ស និងទ្រព្យសម្បត្តិលើទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ភាគីរងគ្រោះដោយមហន្តរាយ និងដើម្បីឆ្លើយតបរួមគ្នាចំពោះគ្រោះអាសន្នតាមរយៈកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិរួមសហប្រត្តិបត្តិការជាមួយថ្នាក់តំបន់ និងអន្តរជាតិ ។ បញ្ហានេះគួរត្រូវសំរបទៅតាមបរិបទទាំងមូល នៃការអភិវឌ្ឍន៍ ជានិរន្តរភាព និងស្របជាមួយបទប្បញ្ញាតិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

## ប្រការទី ៣. គោលការណ៍

ភាគីទាំងឡាយនឹងត្រូវណែនាំដោយគោលការណ៍ទាំងឡាយ ដូចខាងក្រោម : ដើម្បីអនុវត្តក្នុងកិច្ចព្រមព្រៀងនេះ :

១. អធិបតេយ្យភាព បូរណភាពដែនដី និងឯកភាពជាតិនៃភាគីទាំងឡាយនឹងត្រូវបានគោរព ស្របទៅតាមសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ និងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។ ក្នុងស្ថានភាពនេះ ភាគីរងគ្រោះនីមួយៗត្រូវមានការទទួលខុសត្រូវជាបឋមដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលកំពុងកើតឡើងក្នុងដែនដីរបស់ខ្លួន ហើយជំនួយខាងក្រៅ ឬការផ្តល់ជំនួយទាំងឡាយនឹងត្រូវផ្តល់ជូននៅពេលមានសំណើសុំ ឬដោយមានការយល់ព្រមពីរភាគីរងគ្រោះ។

២. ភាគីស្នើសុំ ឬភាគីទទួលជំនួយត្រូវអនុវត្តការណែនាំ ការតាមដាន ការសំរបសំរួល និងការពិនិត្យមើលទាំងមូលនៃជំនួយនៅក្នុងដែនដីប្រចាំខ្លួន។

៣. ក្នុងស្មារតីសាមគ្គីភាព និងភាពជាដៃគូ ស្របតាមតំរូវការជាសមត្ថភាព និងស្ថានភាពភាគីទាំងឡាយត្រូវពង្រឹងកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលដើម្បីសំរេចគោលដៅនៃកិច្ចព្រមព្រៀងនេះ។

៤. ភាគីទាំងឡាយត្រូវផ្តល់អាទិភាពទៅលើការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ ព្រមទាំងអនុវត្តវិធានការប្រុងប្រយ័ត្នដើម្បីត្រៀមបង្ការតាមដាន និងកាត់បន្ថយគ្រោះមហន្តរាយ។

៥. ភាគីទាំងឡាយត្រូវខិតខំប្រឹងប្រែងកាត់បន្ថយយថាភ័យមហន្តរាយនៅគោលនយោបាយអភិវឌ្ឍន៍ជានិរន្តរភាព ការកសាងផែនការ និងកម្មវិធីនៅគ្រប់កំរិត។

៦. ពាក់ព័ន្ធនឹងគ្រោះភ័យនៃមហន្តរាយ ភាគីទាំងឡាយត្រូវរួមបញ្ចូលអោយបានសមស្របនូវដៃគូរបស់ខ្លួនទាំងអស់រួមមានសហគមន៍អង្គការក្រៅរដ្ឋាភិបាល និងសហគ្រាសឯកជនដោយប្រើប្រាស់នូវកម្មវិធីត្រៀមរៀបចំគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន និងការឆ្លើយតមបឋម។

## ប្រការទី ៤. កាតព្វកិច្ចទូទៅ

ក្នុងការអនុវត្តតាមគោលដៅនៃកិច្ចព្រមព្រៀងនេះ ភាគីទាំងឡាយត្រូវ :

ក. ធ្វើសហប្រតិបត្តិការក្នុងការកសាង និងអនុវត្តវិធានការ ដើម្បីកាត់បន្ថយការបាត់បង់ដោយគ្រោះមហន្តរាយរួមមាន ការរកអត្តសញ្ញាណគ្រោះភ័យនៃគ្រោះមហន្តរាយ ការអភិវឌ្ឍន៍នៃការតាមដានត្រួតពិនិត្យ ការវាយតំលៃ និងប្រព័ន្ធជូនដំណឹងជាមុន ការរៀបចំត្រៀមបំរុងសំរាប់ការផ្តល់ជំនួយគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ការផ្លាស់ប្តូរពតិមាន និងបច្ចេកវិទ្យា ព្រមទាំងការផ្តល់ជំនួយទៅវិញទៅមក

ខ. ឆ្លើយតបជាបន្ទាន់ចំពោះគ្រោះមហន្តរាយមួយ ដែលអាចនឹងកើតឡើងនៅក្នុងដែនដីរបស់ខ្លួន ។ នៅពេលគ្រោះមហន្តរាយនេះហាក់ដូចជាអាចបង្កអោយផលប៉ះពាល់ទៅរដ្ឋជាសមាជិកដទៃទៀតត្រូវឆ្លើយតបជាបន្ទាន់ទៅនឹងសំណើសុំព័ត៌មានពាក់ព័ន្ធដែលរដ្ឋជាសមាជិកមួយ ឬច្រើនយល់ឃើញថាអាចទទួលរងការប៉ះពាល់ដោយគ្រោះមហន្តរាយនេះដោយមានគោលបំណងកាត់បន្ថយអោយទៅជាអប្បបរមានូវផលលំបាកទាំងឡាយ

គ. ឆ្លើយតបជាបន្ទាន់ចំពោះសំណើសុំជំនួយពីរភាគីរងគ្រោះព្រមទាំង

ឃ. ចាត់វិធានការច្បាប់រដ្ឋបាល និងវិធានការដទៃទៀតទៅតាមការចាំបាច់ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ។

## ផ្នែកទី II: ការរកអត្តសញ្ញាណ ការប៉ាន់ប្រមាណ និងការតាមដានត្រួតពិនិត្យគ្រោះភ័យនៃគ្រោះមហន្តរាយ

### ប្រការទី ៥. ការរកអត្តសញ្ញាណ និងការតាមដានត្រួតពិនិត្យគ្រោះភ័យ

១. ភាគីនីមួយៗត្រូវចាត់វិធានការសមស្របដើម្បីរកអត្តសញ្ញាណគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងដែនដីរៀងៗខ្លួនដោយរួមមានទិដ្ឋភាពផ្សេងៗ ដូចខាងក្រោម :

ក). មុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

ខ). ការប៉ាន់ប្រមាណគ្រោះភ័យ

គ). ការតាមដានភាពងាយរងគ្រោះ និង

ឃ). សមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ

២. ភាគីទាំងឡាយត្រូវកំណត់កំរិតគ្រោះភ័យចំពោះមុខសញ្ញាគ្រោះថ្នាក់នីមួយៗ ស្របតាមនឹងលក្ខណៈវិនិច្ឆ័យព្រមព្រៀងគ្នា ។

៣. ភាគីនីមួយៗត្រូវធានាថាមន្ត្រីទទួលបន្ទុកជាតិរបស់ខ្លួនប្រាស្រ័យទាក់ទងពត៌មានខាងលើទៅតាមចន្លោះថេរវេលាទៀងទាត់ជាមួយនឹងមជ្ឈមណ្ឌលសំរបសំរួលអាស៊ាន ដើម្បីជំនួយមនុស្សធម៌ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយនិយាយកាត់ខ្លី " មជ្ឈមណ្ឌលAHA " ដែលនឹងត្រូវរៀបចំឡើងស្របតាមប្រការ២០ នៃកិច្ចព្រមព្រៀងនេះ ។

៤. មជ្ឈមណ្ឌល AHA ត្រូវទទួល និងផ្តល់ការគាំទ្រចំពោះទិន្នន័យដូចបានវិភាគ ហើយនឹងផ្តល់អនុសាសន៍ស្តីពី កំរិតគ្រោះភ័យ អំពីមន្ត្រីទទួលបន្ទុកថ្នាក់ជាតិ ។ដោយផ្អែកលើមូលដ្ឋាននៃពត៌មានបែបនេះ មជ្ឈមណ្ឌលAHA ត្រូវចែករំលែកភាគីនីមួយៗតាមរយៈមន្ត្រីទទួលបន្ទុកថ្នាក់ជាតិរបស់ខ្លួននូវទិន្នន័យដែលបានវិភាគឃើញថាសមស្របដឹកនាំការវិភាគទៅលើការអាចរួមបញ្ចូលក្នុងកំរិតថ្នាក់តំបន់ ។

# ផ្នែកទី III: ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់គ្រោះមហន្តរាយ

## ប្រការទី ៦. ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់គ្រោះមហន្តរាយ

១. ភាគីទាំងឡាយត្រូវបានកសាងយុទ្ធសាស្ត្ររួមគ្នា រឺដោយឡែកដើម្បីរកអត្តសញ្ញាណត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យកើតចេញពីមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ។

២. ភាគីនីមួយៗត្រូវចាត់វិធានការដើម្បីកាត់បន្ថយនូវការបាត់បង់ទាំងឡាយ អំពីគ្រោះមហន្តរាយ ដោយរួមមាន:

ក). កសាង និងអនុវត្តវិធានការច្បាប់ និងវិធានការនៃបទប្បញ្ញត្តិដទៃទៀត ក៏ដូចជាគោលនយោបាយ ផែនការ កម្មវិធីយុទ្ធសាស្ត្រផ្សេងៗ

ខ). ពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ និងការសំរបសំរួល

គ). ជំរុញលើកទឹកចិត្តដល់ការយល់ដឹងនៃការអប់រំសាធារណៈ ព្រមទាំងពង្រឹងការចូលរួមរបស់សហគមន៍ និង

ឃ). ជំរុញលើកទឹកចិត្ត និងការប្រើប្រាស់ចំណេះដឹង និងការអនុវត្តន៍របស់ជនជាតិដើម

៣. ភាគីទាំងឡាយត្រូវសហប្រត្តិបត្តិការគ្នាក្នុងការកសាង និងអនុវត្តន៍កម្មវិធីត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយថ្នាក់តំបន់ ដើម្បីបំពេញភារៈកិច្ចនៅលើការខិតខំប្រឹងប្រែងកំរិតថ្នាក់ជាតិ។

# ផ្នែកទី IV: ការត្រៀមរៀបចំគ្រោះមហន្តរាយ

## ប្រការទី ៧. ការប្រកាសប្រាប់អោយដឹងជាមុននូវគ្រោះមហន្តរាយ

១. ភាគីទាំងឡាយត្រូវរៀបចំថែរក្សា និងពិនិត្យមើលឡើងវិញនូវការរៀបចំការប្រកាសប្រាប់អោយដឹងជាមុនពីគ្រោះមហន្តរាយរួមមាន :

ក). ការវាយតំលៃ គ្រោះភ័យ នៃមហន្តរាយអោយបានទៀងទាត់

ខ). ប្រព័ន្ធពតិមានប្រកាសប្រាប់អោយដឹងជាមុន

គ). បណ្តាញប្រាស្រ័យទាក់ទងគ្នា សំរាប់ផ្តល់ជូនពតិមានទាន់ពេល និង

ឃ). ការយល់ដឹងសាធារណៈ និងការត្រៀមរៀបចំដើម្បីធ្វើសកម្មភាពនៅពេលទទួលបាននូវព័តិមានប្រកាសប្រាប់អោយដឹងជាមុន

២. ភាគីទាំងឡាយត្រូវសហប្រត្តិបត្តិការសមស្រប ដើម្បីតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ដែលបានប៉ះពាល់ឆ្លងដែន ដើម្បីផ្លាស់ប្តូរពតិមានគ្នា និងផ្តល់ពតិមានប្រកាសប្រាប់អោយដឹងមុនតាមរយៈការរៀបចំសមស្រប ។

## ប្រការទី ៩. ការត្រៀមរៀបចំ

១. ភាគីទាំងឡាយត្រូវរួមគ្នា ឬដោយឡែកពីគ្នា កសាងយុទ្ធសាស្ត្រ និងផែនការត្រៀមបំរុងឆ្លើយតបដើម្បីកាត់បន្ថយការបាត់បង់ពីគ្រោះមហន្តរាយ

២. ភាគីទាំងឡាយបើយល់ឃើញថាសមស្របត្រូវរៀបចំនីតិវិធីប្រត្តិបត្តិការជាគំរូសំរាប់កិច្ចសហប្រត្តិបត្តិការ និងសកម្មភាពថ្នាក់ជាតិ ដែលតំរូវដោយក្រោមកិច្ចព្រមព្រៀងនេះរួមមានៈ

   ក). ការរៀបចំបំរុងថ្នាក់តំបន់ សំរាប់ជំនួយសង្គ្រោះ និងការឆ្លើយតបសង្គ្រោះបន្ទាន់

   ខ). ប្រើប្រាស់បុគ្គលិក ត្រៀមបរិក្ខារ ដឹកជញ្ជូនគមនាគមន៍ មូលដ្ឋានសំភារៈ និងសេវាកម្មស៊ីវិល និងយោធា ព្រមទាំងទទួលលក្ខណៈងាយស្រួលដល់ចលនាឆ្លងកាត់ព្រំដែនរបស់គេ និង

   គ). សំរបសំរួលការជួយសង្គ្រោះមហន្តរាយរួមគ្នា និងប្រត្តិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់

៣. ភាគីទាំងឡាយត្រូវរួមគ្នា ឬដោយឡែកពីគ្នាលើកកំពស់សមត្ថភាពថ្នាក់ជាតិរបស់ខ្លួនទៅតាមភាពសមស្របក្នុងនោះមានៈ

   ក). បង្កលក្ខណៈងាយស្រួលដល់ការប្រមែប្រមូលធនធានថ្នាក់ជាតិ ដើម្បីជួយគាំទ្រការរៀបចំត្រៀមបំរុងថ្នាក់តំបន់បែបនេះសំរាប់ជំនួសង្គ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់

   ខ). សំរបសំរួលជាមួយគណៈកម្មាធិការត្រៀមបំរុងស្បៀងអាស៊ាន ដើម្បីបង្កើនលក្ខណៈងាយស្រួល និងការបញ្ចេញអង្ករពីឃ្លាំងបំរុងអង្ករសង្គ្រោះបន្ទាន់អាស៊ាន និង

   គ). ដឹកនាំការបណ្តុះបណ្តាល និងលំហាត់ដើម្បីឈានទៅសំរេច និងរក្សាខ្ជាប់នូវការងារពាក់ព័ន្ធ និងការអនុវត្តន៍តាមនីតិវិធីប្រត្តបត្តិការជាគំរូនេះ ។

៤. ភាគីទាំងឡាយត្រូវផ្តល់ពតិមានអោយបានទៀងទាត់ដល់មជ្ឈមណ្ឌលអាហារ (AHA) ស្តីពីធនធានអាចប្រើប្រាស់បានសំរាប់ការរៀបចំបំរុងថ្នាក់តំបន់ ដើម្បីជួយសង្គ្រោះមហន្តរាយ និងឆ្លើយតបសង្គ្រោះបន្ទាន់ ។

៥. មជ្ឈមណ្ឌល AHA ត្រូវបង្កលក្ខណៈងាយស្រួលដល់ការរៀបចំការថែរក្សា និងការពិនិត្យមើលឡើងវិញទៅតាមកាលវេលានៃការរៀបចំបំរុងថ្នាក់តំបន់សំរាប់ការជួយសង្គ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ ។

៦. មជ្ឈមណ្ឌល AHA ត្រូវបង្កលក្ខណៈងាយស្រួលដល់ការពិនិត្យឡើងវិញទៅតាមពេលវេលានូវនីតិវិធីប្រត្តិបត្តិការជាគំរូ ។

### ប្រការទី ៩. ការរៀបចំបំរុងអាស៊ានសំរាប់ការជួយសង្គ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់

១. ដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត ភាគីនីមួយៗត្រូវកំនត់បំរុងទុកនូវទ្រព្យសម្បត្តិ និងសមត្ថភាពដែលមានប្រើប្រាស់បានសំរាប់ការរៀបចំបំរុងថ្នាក់តំបន់ក្នុងការជួយសង្គ្រោះមហន្តរាយ និងឆ្លើយតមសង្គ្រោះបន្ទាន់ដូចជា

ក). បញ្ជីឈ្មោះ និងអាសយដ្ឋានក្រុមឆ្លើយតប សង្គ្រោះបន្ទាន់ រុករក និងសង្គ្រោះ

ខ). ទ្រព្យសម្បត្តិស៊ីវិល និងយោធា

គ). ឃ្លាំងស្តុក សង្គ្រោះបន្ទាន់ នៃសំភារៈជួយសង្គ្រោះ

ឃ). ជំនាញការបច្ចេកវិទ្យាគ្រប់គ្រងមហន្តរាយ

២. ទ្រព្យសម្បត្តិ និងសម្ថភាពកំនត់បំរុងនេះឱ្យផ្តល់ពតិមានជូនខាងភាគីនីមួយៗ ក៏ដូចជាទៅអោយមជ្ឈមណ្ឌល AHA ព្រមទាំងបបញ្ជាក់សភាពបច្ចុប្បន្ន ដោយភាគីជាប់ទាក់ទង ។

៣. មជ្ឈមណ្ឌលAHA ត្រូវគាំទ្របញ្ជាក់សភាពបច្ចុប្បន្ននិងចែករំលែកទិន្និន័យស្តីពីទ្រព្យសម្បត្តិនិងសមត្ថភាពកំនត់បំរុងទុកនេះរួចជូនដំណឹងទៅភាគីទាំងឡាយសំរាប់ការប្រើប្រាស់ ។

៤. ដើម្បីជួយសំរួលដល់ការប្រើប្រាស់នៃទ្រព្យសម្បត្តិរៀបរាប់នៅកថាខណ្ឌទី១ ភាគីនីមួយៗត្រូវរៀបចំបណ្តាញមួយនៃតំបន់មុនពេលរៀបចំធ្វើជាចំណុចចូលសំរាប់សំភារៈផ្គត់ផ្គង់ និងជំនាញការអំពីភាគីជួយ ។

## ផ្នែកទី V: ការឆ្លើយតបសង្គ្រោះបន្ទាន់

### ប្រការទី ១០. ការឆ្លើយតបសង្គ្រោះបន្ទាន់ថ្នាក់ជាតិ

១. ភាគីនីមួយៗដោយអនុលោមទៅតាមច្បាប់បញ្ញាតិថ្នាក់ជាតិរបស់ខ្លួនត្រូវធានាថាវិធានការចាំបាច់សំរាប់ការកៀរគរគ្រឿងបរិក្ខារ មូលដ្ឋានសំភារៈ ធនធានមនុស្ស និងហិរញ្ញវត្ថុត្រូវការទាមទារឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ។

២. ភាគីនីមួយៗអាចផ្តល់ពតិមានជាបន្ទាន់ដល់ភាគីដទៃទៀត និងមជ្ឈមណ្ឌលសំរបសំរួលជំនួយមនុស្សធមិអាស៊ាន (AHA) ដល់វិធានការនេះ ។

### ប្រការទី ១១. ការឆ្លើយតបសង្គ្រោះបន្ទាន់រួចគ្នាតាមរយៈការផ្តល់ជំនួយ

១. ប្រសិនបើភាគីមួយត្រូវការជំនួយក្នុងព្រឹត្តិការណ៍សង្គ្រោះបន្ទាន់ចំពោះគ្រោះមហន្តរាយនៅ

ក្នុងដែនដីរបស់ខ្លួន ភាគីនេះអាចស្នើសុំជំនួយបែបនេះពីភាគីដទៃទៀតដោយផ្ទាល់ ឬតាមរយៈមជ្ឈមណ្ឌល AHA ឬពីអង្គភាពដទៃទៀតបើយល់ថាមានភាពសមស្រប

២. ជំនួយគ្រាន់តែអាចត្រូវបានបញ្ជូនទៅតាមសំណើសុំ ហើយដោយមានការយល់ព្រមគ្នារបស់ភាគីស្នើសុំ ឬនៅពេលផ្តល់ជូនដោយភាគីមួយទៀត ឬភាគីច្រើនដោយមានការយល់ព្រមគ្នារបស់ភាគីទទួលជំនួយ ។

៣. ភាគីស្នើសុំត្រូវបញ្ជាក់ច្បាស់ពីទំហំ និងប្រភេទជំនួយត្រូវការព្រមទាំងផ្តល់ជូនដល់អង្គភាពជំនួយនូវពតិមានបែបនេះទៅតាមការចាំបាច់សំរាប់ភាគីនោះ កំណត់ពីទំហំដែលខ្លួនអាចដោះស្រាយបានចំពោះសំណូមពរក្នុងករណីពុំអាចអនុវត្តន៍បានសំរាប់ភាគីស្នើសុំ ដើម្បីកំណត់ច្បាស់ពីទំហំ និងប្រភេទនៃជំនួយត្រូវការភាគីស្នើសុំ និងភាគីផ្តល់ជំនួយត្រូវវាយតំលៃរួមគ្នាតាមរយៈការពិគ្រោះយោបល់គ្នា និងសំរេចិត្តទៅលើទំហំ និងប្រភេទនៃជំនួយដែលត្រូវការនេះ ។

៤. ភាគីនីមួយៗ ដែលសំណើសុំផ្តល់ជំនួយត្រូវបានបញ្ជូនមកត្រូវសំរេចិត្តភ្លាមៗ និងជូនដំណឹងទៅភាគីស្នើសុំដោយផ្ទាល់ឬតាមរយៈមជ្ឈមណ្ឌលAHAទោះបីស្ថិតក្នុងស្ថានភាពផ្តល់ជំនួយដែលស្នើសុំអំពីទំហំនិងស្ថានភាពនៃជំនួយនេះ ។

៥. ភាគីនីមួយៗ ដែលការផ្តល់ជំនួយត្រូវបានបញ្ជូនមកអោយត្រូវសំរេចចិត្តភ្លាមៗ និងជូនដំណឹងទៅភាគីផ្តល់ជំនួយដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌល AHA ទោះបីស្ថិតក្នុងស្ថានភាពអ្នកយល់ព្រមយកជំនួយដែលផ្តល់ជូនព្រមទាំងពីទំហំ និងស្ថានភាពជំនួយនេះ ។

៦. ភាគីទាំងឡាយនៅក្នុងក៏រិតព្រំដែននៃសមត្ថភាពរបស់ខ្លួនត្រូវរកអោយឃើញ និងជូនដំណឹងដល់មជ្ឈមណ្ឌល AHA នូវបុគ្គលិកយោធា និងស៊ីវិល អ្នកជំនាញការ គ្រឿងបរិក្ខារ មធ្យោបាយ និងសំភារៈដែលអាចត្រូវបានផ្តល់ជូនក្រោមស្ថានភាពជំនួយនេះ ។

## ប្រការទី ១២. ការដឹកនាំ និងការត្រួតពិនិត្យជំនួយ

វៀរលែងតែមានការព្រមព្រៀងក្រៅពីនេះទៀត :

១. ភាគីស្នើសុំ ឬភាគីទទួលជំនួយត្រូវអនុវត្តការដឹកនាំ ការត្រួតពិនិត្យ ការសំរបសំរួល និងការឃ្លាំមើលពីលើនៃជំនួយនៅលើទឹកដីរបស់ខ្លួន ។ ភាគីផ្តល់ជំនួយប្រសិនបើជំនួយមានការចូលរួមពីបុគ្គលិកយោធា និងមន្ត្រីស៊ីវិលពាក់ព័ន្ធត្រូវចាត់តាំងមនុស្សម្នាក់តាមការពិគ្រោះយោបល់ជាមួយភាគីស្នើសុំ ឬទទួលជំនួយដែលនឹងទទួលបន្ទុកនូវការឃ្លាំមើលពីលើប្រត្តិបត្តិការភ្លាមៗចំពោះបុគ្គលិក និងត្រៀមបរិក្ខាផ្តល់ជូន ។ បុគ្គលដែលទទួលចាត់តាំងក្នុងនាមប្រធានប្រត្តិបត្តិការផ្តល់ជំនួយត្រូវអនុវត្តនូវការឃ្លាំមើលពីលើនេះជាមួយអាជ្ញាធរតាមលំដាប់ថ្នាក់របស់ភាគីស្នើសុំ ឬទទួលជំនួយ ។

២. ភាគីស្នើសុំ ឬទទួលជំនួយត្រូវយកអស់លទ្ធភាពផ្តល់ជូននូវមូលដ្ឋានសំភារៈ និងសេវាកម្ម

ក្នុងស្រុកសំរាប់ការងាររដ្ឋបាលសមស្រប និងប្រសិទ្ធភាពនៃជំនួយ។ ភាគីនេះក៏ត្រូវធានានូវកិច្ចការពារដល់បុគ្គលិក គ្រឿងបរិក្ខា និងសំភារៈ ដែលនាំយកមកក្នុងទឹកដីរបស់ខ្លួន ហើយ ឬក្នុងនាមនៃភាគីផ្តល់ជំនួយសំរាប់គោលបំណងនេះ។បុគ្គលិកយោធា និងមន្ត្រីស៊ីវិលពាក់ព័ន្ធមិនត្រូវកាន់អាវុធក្នុងដៃ។

៣. ភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយត្រូវពិនិត្យពិគ្រោះយោបល់ និងសំរបសំរួលជាមួយគ្នាទៅវិញទៅមក និងការតវ៉ាណាមួយជាជាងធ្វើអំពើតវ៉ាប្រឆាំងគ្នាអំពីការធ្វេសប្រហែស ឬកិច្ចសន្យាដែលនាំអោយមានការខូចខាត ការបាត់បង់ ឬការបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ឬបង្ករបួស ឬស្លាប់ដល់បុគ្គលិកនៃភាគីទាំងពីរដែលកើតចេញឡើងពីការអនុវត្តន៏ភារកិច្ចជាផ្លូវការរបស់គេ។

៤. ទំនិញ និងសំភារៈសំរាប់ការសង្គ្រោះដែលផ្តល់ដោយភាគីផ្តល់ជំនួយ គប្បីមានគុណភាព និងសុពលភាពស្របតាមតំរូវការនៃភាគីទាំងឡាយពាក់ព័ន្ធសំរាប់ហូបចុក និងប្រើប្រាស់។

## ប្រការទី ១៣. ការគោរពច្បាប់ និងបទប្បញ្ញត្តិជាតិ

១. សមាជិកនៃក្រុមប្រត្តិបត្តិការផ្តល់ជំនួយត្រូវបញ្ឈប់នូវអំពើ ឬសកម្មភាពណាដែលមិនសមស្របនឹងលក្ខណៈ និងគោលបំណងនៃកិច្ចព្រមព្រៀង។

២. សមាជិកនៃក្រុមប្រត្តិបត្តិការជំនួយត្រូវគោរព និងអនុវត្តន៏តាមច្បាប់ និងបទប្បញ្ញត្តិជាតិ។ ប្រធានក្រុមប្រត្តិបត្តិការផ្តល់ជំនួយត្រូវចាត់វិធានការសមស្រប ដើម្បីធានាដល់ការគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាតិនេះ។ ភាគីទទួលជំនួយត្រូវសហប្រត្តិបត្តិការដើម្បីធានាថាសមាជិកនៃក្រុមប្រត្តិបត្តិការផ្តល់ជំនួយគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាតិ។

## ប្រការទី ១៤. ការលើកលែងពន្ធ និងមូលដ្ឋានសំភារៈក្នុងក្របខ័ណ្ឌនៃការផ្តល់ជំនួយ

ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញាត្តិជាតិ ភាគីស្នើសុំ ឬទទួលជំនួយត្រូវ :

ក). យល់ព្រមអោយភាគីផ្តល់ជំនួយទទួលនូវការលើកលែងពន្ធអាករ និងចេញចំណាយដទៃក្នុងប្រភេទដូចគ្នានេះចំពោះការនាំចូល និងការប្រើប្រាស់គ្រឿងបរិក្ខារ រួមទាំងយានជំនិះនិងទូរគមន៏មូលដ្ឋាន សំភារៈ និងគ្រឿងសំភារៈផ្សេងៗនាំចូលក្នុងដែនដីខេត្តភាគីស្នើសុំ ឬទទួលជំនួយសំរាប់គោលបំណងផ្តល់ជំនួយ។

ខ). បង្កភាពងាយស្រួលដល់ការចូលស្នាក់នៅ និងចេញដំណើររបស់បុគ្គលិក និងគ្រឿងបរិក្ខា មធ្យោបាយសំភារៈ និងគ្រឿងសំភារៈផ្សេងៗក្នុងក្របខ័ណ្ឌនៃការផ្តល់ជំនួយ។

គ). សហប្រត្តិបត្តិការអោយបានសមស្របជាមួយមជ្ឈមណ្ឌល AHA ដើម្បីបង្កើនភាពងាយស្រួលដល់ដំណើរការលើកលែងពន្ធ នៅមូលដ្ឋានសំភារៈក្នុងក្របខ័ណ្ឌនៃការផ្តល់ជំនួយ។

## ប្រការទី ១៥. អត្តសញ្ញាណកម្ម

១. បុគ្គលិកយោធា និងមន្ត្រីស៊ីវិលពាក់ពន្ធ័ដែលចូលរួមក្នុងប្រតិបត្តិការផ្តល់ជំនួយត្រូវបានអនុញ្ញាតអោយស្លៀកពាក់ឯសណ្ឋានដោយកំណត់អត្តសញ្ញាណកម្មដាច់ពីគ្នាក្នុងពេលបំពេញភារកិច្ចជាផ្លូវការ ។

២. សំរាប់គោលបំណងចូល និងចេញដំណើរពីដែនដីរបស់ភាគីទទួលជំនួយសមាជិកនៃក្រុមប្រតិបត្តិការនេះត្រូវមាន:

ក). បញ្ជាធ្វើសកម្មភាពមួយជាបុគ្គលឬសមូហភាពដែលចេញដោយ រឺក្រោមអាជ្ញាធរនៃប្រធានក្រុមប្រតិបត្តិការផ្តល់ជំនួយ ឬក្រោមអាជ្ញាធរសមស្របណាមួយរបស់ភាគីផ្តល់ជំនួយព្រមទាំង

ខ). អត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនមួយចេញដោយអាជ្ញាធរសមស្របនៃភាគីផ្តល់ជំនួយ

៣. យន្តហោះ និងនាវាដែលប្រើប្រាស់ដោយបុគ្គលិកយោធា និងមន្ត្រីស៊ីវិលពាក់ព័ន្ធនៃគាភីផ្តល់ជំនួយអាចប្រើប្រាស់ដោយការចុះបញ្ជីរបស់ខ្លួន និងផ្លាកលេខអនុញ្ញាតដែលងាយចំណាំរបស់ខ្លួនដោយពុំមានបង់ពន្ធផ្លូវការជាអាជ្ញាប័ណ្ណ និង/ឬ លិខិតអនុញ្ញាតដ៏ទៃទៀត ។ យន្តហោះយោធាទាំងអស់ដែលទទួលការអនុញ្ញាត និងត្រូវបានចាត់ទុកជាយន្តហោះមិត្តនិងយល់ព្រមអោយបើកប្រេកង់វិទ្យុ និងអត្តញ្ញាណកម្មមិត្ត ឬសត្រូវ (IFF) ដោយអាជ្ញាធរនៃភាគីទទួលជំនួយ ។

## ប្រការទី ១៦. ការឆ្លងកាត់របស់បុគ្គលិក បរិក្ខារ មូលដ្ឋានសំភារៈ និងសំភារៈផ្សេងៗ ក្នុងក្របខ័ណ្ឌនៃការផ្តល់ជំនួយ

១. ពេលមានសំណើរសុំរបស់ភាគីពាក់ព័ន្ធ ភាគីនីមួយៗត្រូវស្វែងរកការបង្កលក្ខណៈងាយស្រួលដល់ការឆ្លងកាត់នៃបុគ្គលិក បរិក្ខារ មូលដ្ឋានសំភារៈ និងសំភារៈផ្សេងៗ ដែលជួយដល់ដំណើរការដ៏ត្រឹមត្រូវតាមរយៈដែនដីរបស់ខ្លួនដែល និងចូលរួមឬប្រើប្រាស់នៅក្នុងការផ្តល់ជំនួយចំពោះភាគីស្នើសុំ ឬទទួលជំនួយ ។ ភាគីពាក់ព័ន្ធត្រូវទទួលការលើកលែងពន្ធអាករ និងការបន្ទុកចំណាយទទួលផ្សេងៗ ដែលមានលក្ខណៈដូចគ្នា និងបរិក្ខារមូលដ្ឋានសំភារៈផ្សេងៗបែបនេះ ។

២. មជ្ឈមណ្ឌល AHA បើយល់ថាមានលទ្ធភាព និងមានភាពសមស្របត្រូវបង្កភាពងាយស្រួលដល់ដំណើរការឆ្លងកាត់របស់បុគ្គលិក បរិក្ខារ មូលដ្ឋានសំភារៈ និងសំភារៈផ្សេងៗក្នុងក្របខណ្ឌនៃការផ្តល់ជំនួយ ។

# ផ្នែកទី VI: ការស្តារឡើងវិញ

## ប្រការទី ១៧. ការស្តារឡើងវិញ

ក្នុងគោលបំណងអនុវត្តន៍កិច្ចព្រមព្រៀងនេះ ភាគីទាំងឡាយត្រូវរួមគ្នា ឬជាបុគ្គល កសាងយុទ្ធសាស្រ្ត និងអនុវត្តន៍កម្មវិធី សំរាប់ការស្តារឡើងវិញ ក្នុងក្របខណ្ឌជាលទ្ធផលនៃគ្រោះមហន្តរាយ ។ ភាគីទាំងឡាយត្រូវលើកទឹកចិត្តអោយបានសមស្របដល់កិច្ចសហប្រតិបត្តិការទ្វេរភាគីថ្នាក់តំបន់ និងអន្តរជាតិសំរាប់ស្តារឡើងវិញក្នុងក្របខណ្ឌជាលទ្ធផលនៃគ្រោះមហន្តរាយ ។

# ផ្នែកទី VII: កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការស្រាវជ្រាវវិទ្យាសាស្រ្ត

## ប្រការទី ១៨. កិច្ចសហប្រតិបត្តិការបច្ចេកទេស

១. ដើម្បីបង្កើនការត្រៀមរៀបចំ និងកាត់បន្ថយគ្រោះថ្នាក់នៃគ្រោះមហន្តរាយ ភាគីទាំងឡាយត្រូវអនុវត្តន៍កិច្ចសហប្រតិបត្តិការបច្ចេកទេស រួមមានដូចតទៅ:

ក). បង្កភាពងាយស្រួលដល់ការកៀរគរធនធានសមស្របទាំងនៅក្នុង និងខាងក្រៅភាគីទាំងឡាយ

ខ). លើទឹកចិត្តដល់ការកសាងគំរូស្តង់ដានៃទំរង់របាយការណ៍អំពីទិន្នន័យ និងពតិមាន

គ). លើទឹកចិត្តដល់ការផ្លាស់ប្តូរពតិមានពាក់ព័ន្ធផ្នែកជំនាញបច្ចេកវិទ្យា បច្ចេកទេស និងចំណេះដឹង

ឃ). ផ្តល់ ឬធ្វើការរៀបចំសំរាប់ការងារបណ្តុះបណ្តាលពាក់ព័ន្ធការអប់រំយល់ដឹងជាសាធារណៈជាពិសេសទាក់ទងនិងការត្រៀមបង្ការ និងកាត់បន្ថយគ្រោះថ្នាក់នៃគ្រោះមហន្តរាយ

ង). កសាង និងអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលសំរាប់អ្នកកសាងគោលនយោបាយ អ្នកគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ព្រមទាំង

ច). ពង្រឹង និងលើកកំពស់សមត្ថភាពបច្ចេកទេសរបស់ភាគីទាំងឡាយ ដើម្បីអនុវត្តន៍កិច្ចព្រមព្រៀង ។

២. មជ្ឈមណ្ឌល AHA ត្រូវបង្កភាពងាយស្រួលដល់សកម្មភាពសំរាប់កិច្ចសហប្រតិបត្តិការដូចបង្ហាញនៅកថាខណ្ឌទី ១ ខាងលើ ។

## ប្រការទី ១៩. ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស

៣. ភាគីទាំងឡាយ ជាបុគ្គល ឬរួមគ្នា រួមទាំងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ សមស្រមត្រូវលើកទឹកចិត្ត ហើយនៅពេលណាមានលទ្ធភាពត្រូវជួយគាំទ្រដល់កម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេសទាក់ទង និងមូលហេតុ និងផលវិបាកនៃគ្រោះមហន្តរាយ ព្រមទាំងគាំទ្រដល់មធ្យោបាយវិធីសាស្ត្រ បច្ចេកទេស និងគ្រឿងបរិក្ខាសំរាប់កាត់បន្ថយគ្រោះភ័យនៃមហន្តរាយ ។ក្នុងករណីនេះការការពារសិទ្ធកម្មសិទ្ធបញ្ញារបស់ភាគីទាំងឡាយពាក់ព័ន្ធត្រូវតែទទួលបានការគោរព ។

៤. មជ្ឈមណ្ឌល AHA ត្រូវបង្កភាពងាយស្រួល ដល់សកម្មភាពទាំងឡាយសំរាប់ការស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកទេសដូចបានបង្ហាញនៅកថាខណ្ឌទី១ ខាងលើ ។

# ផ្នែកទី VIII: មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជួយមនុស្សធម៌

## ប្រការទី ២០. មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជំនួយមនុស្សធម៌

១. មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជំនួយមនុស្សធមិខាងផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ (មជ្ឈមណ្ឌល AHA ) និងត្រូវបានរៀបចំឡើង ក្នុងគោលបំណងបង្កភាពងាយស្រួលដល់កិច្ចសហប្រតិបត្តិការ និងការសំរបសំរួលក្នុងចំណោមភាគីទាំងឡាយ និងជាមួយអង្គការសហប្រជាជាតិ និងអង្គការអន្តជាតិពាក់ព័ន្ធដោយលើកទឹកចិត្តដល់កិច្ចសហការក្នុងតំបន់ ។

២. មជ្ឈមណ្ឌលAHA ត្រូវធ្វើការដោយផ្អែកលើមូលដ្ឋានដែលភាគី និងធ្វើសកម្មភាពជាមុនក្នុងការគ្រប់គ្រង ឆ្លើយតបចំពោះគ្រោះមហន្តរាយ ។ នៅក្នុងករណីដែលភាគីទាមទារត្រូវការជំនួយដើម្បីដោះស្រាយជាមួយស្ថានភាពបែបនេះបន្ថែមទៅលើសំណើរសុំផ្ទាល់ទៅកាន់ភាគីជំនួយភាគីនោះអាចស្វែងរកជំនួយអំពីមជ្ឈមណ្ឌល AHA ដើម្បីបង្កភាពងាយស្រួលដល់សំណើរសុំបែបនេះ ។

៣. មជ្ឈមណ្ឌល AHA ត្រូវបំពេញមុខងាររបស់ខ្លួនដូចដាក់ចេញនៅក្នុងឧបសម្ព័ន្ធ និងមុខងារដទៃទៀតដូចជាណែនាំនៅសន្និសីទនៃភាគីទាំងឡាយ ។

# ផ្នែកទី IX: ការរៀបចំស្ថាប័ន

## ប្រការទី ២១. សន្និសីទនៃភាគីទាំងឡាយ

១. សន្និសីទមួយនៃភាគីទាំងឡាយ ត្រូវបានរៀបចំឡើងនៅក្នុងកិច្ចព្រមព្រៀងនេះ។ ការប្រជុំលើកទី១ នៃសន្និសីទរបស់ភាគីទាំងឡាយ និងត្រូវកោះប្រជុំដោយលេខាធិការដ្ឋាន មិនអោយហួសពីរយៈពេលមួយឆ្នាំក្រោយពេលចូលជាធរមាននៃកិច្ចព្រមព្រៀង។ ក្រោយមកការប្រជុំសាមញ្ញទាំងឡាយនៃសន្និសីទរបស់ភាគីទាំងឡាយត្រូវបន្តដោយប្រព្រឹត្តទៅយ៉ាងហោចមួយដងនៅរៀងរាល់ឆ្នាំទៅតាមលទ្ធភាពរួមជាមួយការប្រជុំសមស្របផ្សេងៗទៀតរបស់អាស៊ាន។

២. ការប្រជុំវិសាមញ្ញទាំងឡាយត្រូវប្រព្រឹត្តទៅនៅពេលវេលាស្របទៅតាមសំណើរសុំរបស់ភាគីមួយដែលផ្តល់ជូនជាសំណើរសុំបែបនេះត្រូវបានគាំទ្រយ៉ាងហោចណាស់ដោយភាគីមួយទៀត។

៣. សន្និសីទនៃភាគីទាំងឡាយត្រូវស្ថិតនៅក្រោមរបៀបវារៈ ពិនិត្យមើលឡើងវិញជាបន្តបន្ទាប់ វាយតំលៃចំពោះការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ ហើយដើម្បីសំរេចគោលបំណងនេះត្រូវៈ

- ក). ធ្វើសកម្មភាពបែបនេះ បើមានការចាំបាច់ដើម្បីធានាដល់ការអនុវត្តន៍កិច្ចព្រមព្រៀងប្រកបដោយប្រសិទ្ធិភាព។
- ខ). ពិនិត្យមើលរបាយការណ៍ និងពត៌មានដទៃទៀត ដែលភាគីអាចដាក់ជូនដោយផ្ទាល់ ឬតាមរយៈលេខាធិការដ្ឋាន ។
- គ). ពិនិត្យមើល និងពិធីសារស្របទៅតាមប្រការទី២៥ នៃកិច្ចព្រមព្រៀងនេះ
- ឃ). ពិនិត្យមើល និងធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះ
- ង). អនុវត្តយកពិនិត្យដមើលឡើងវិញ និងធ្វើវិសោធនកម្មទៅតាមតំរូវការរបស់ឧបសម្ព័ន្ធទាំងឡាយណាចំពោះកិច្ចព្រមព្រៀងនេះ
- ច). រៀបចំយន្តការបន្ទាប់បន្សំទាំងឡាយទៅតាមតំរូវការសំរាប់ការអនុវត្ត នៃកិច្ចព្រមព្រៀងនេះព្រមទាំង
- ឆ). ពិនិត្យមើល និងធ្វើសកម្មភាពបន្ថែមណាមួយដែលអាចត្រូវការសំរាប់ការសំរេចគោលដៅនៃកិច្ចព្រមព្រៀងនេះ។

## ប្រការទី ២២. មន្ត្រីទទួលបន្ទុកថ្នាក់ជាតិ និងអាជ្ញាធរមានសមត្ថកិច្ច

១. ភាគីនីមួយៗត្រូវចាប់តាំងមន្ត្រីទទួលបន្ទុកម្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចមួយ ឬលើសពី

នេះក្នុងគោលបំណងអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

២. ភាគីនីមួយៗត្រូវជូនព័ត៌មានដល់ភាគីដទៃទៀត និងមជ្ឈមណ្ឌល AHA អំពីមន្ត្រីទទួលបន្ទុកជាតិ និងអាជ្ញាធរ មានសមត្ថកិច្ចរបស់ខ្លួនព្រមទាំងការផ្លាស់បន្តូរបន្ទាប់ណាមួយនៅក្នុងការចាត់តាំងរបស់គេ ។

៣. មជ្ឈមណ្ឌល AHA ផ្តល់ជូនដោយទៀងទាត់ និងទាន់ពេលវេលាទៅកាន់ភាគីទាំងឡាយ ហើយបើយល់ថាចាំបាច់ទៅកាន់អង្គការអន្តរជាតិពាក់ព័ន្ធនូវពតិមានដោយយោងទៅលើកថាខណ្ឌទី២ ខាងលើ ។

## ប្រការទី ២៣. លេខាធិការដ្ឋាន

១. លេខាធិការដ្ឋានអាស៊ាន ត្រូវបំរើការលេខាធិការដ្ឋានដល់កិច្ចព្រមព្រៀងនេះ ។

២. មុខងារនៃលេខាធិការដ្ឋានត្រូវរួមបញ្ចូលដូចតទៅ :

ក). រៀបចំសំរាប់ការងារប្រជុំទាំងឡាយរបស់សិន្និសីទនៃភាគីទាំងឡាយនិងរបស់អង្គការដទៃទៀតដែលរៀបចំឡើងដោយកិច្ចព្រមព្រៀងនេះ ។

ខ). បញ្ជូនទៅកាន់ភាគីទាំងឡាយនូវការជូនដំណឹងរបាយការណ៍ និងព័ត៌មានដទៃទៀតដែលទទួលបានស្របទៅ និងកិច្ចព្រមព្រៀងនេះ

គ). ពិនិត្យមើលសំណូមពរទាំងឡាយ និងព័ត៌មានរបស់ភាគីទាំងឡាយព្រមទាំងពិគ្រោះយោបល់ជាមួយគេស្តីពីបញ្ហាទាក់ទងទៅ និងកិច្ចព្រមព្រៀងនេះ

ឃ). ធានានូវការសំរបសំរួលចំបាច់ជាមួយអង្គការអន្តរជាតិពាក់ព័ន្ធ និងជាពិសេសចូលរួមក្នុងការរៀបចំផ្នែករដ្ឋបាលដែលអាចត្រូវការសំរាប់ផ្ទេរជូនដោយប្រសិទ្ធភាពនូវមុខងាររបស់លេខាធិការដ្ឋានព្រមទាំង

ង). បំពេញមុខងារដទៃទៀតដែលអាចចាត់តាំងដោយភាគីទាំងឡាយ ។

## ប្រការទី ២៤. ការរៀបចំហិរញ្ញវត្ថុ

១. មូលនិធិមួយត្រូវបានរៀបចំឡើងសំរាប់ការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ ។

២. មូលនិធិនេះនឹងត្រូវមានឈ្មោះជាមូលនិធិគ្រប់គ្រង់គ្រោះមហន្តរាយ និងជួយសង្គ្រោះបន្ទាន់អាស៊ាន ។

៣. មូលនិធិនេះត្រូវអភិបាលដោយលេខាធិកាដ្ឋានអាស៊ានក្រោមការណែនាំរបស់សន្និសីទនៃភាគីទាំងឡាយ ។

៤. ភាគីទាំងឡាយដោយអនុលោមទៅតាមសេចក្តីសំរេចរបស់សន្និសីទនេះភាគីទាំងឡាយត្រូវចូលវិភាគទានតាមការស្ម័គ្រចិត្តទៅអោយមូលនិធិនេះ ។

៥. មូលនិធិនេះត្រូវបើកចំហរជូនការរួមវិភាគទានអំពីប្រភពផ្សេងៗទៀតដោយអនុលោមទៅតាមសេចក្តីសំរេច ឬការយល់ព្រមរបស់ភាគីទាំងឡាយ ។

៦. ភាគីទាំងឡាយបើមានការចាំបាច់អាចកៀរគរធនធានបន្ថែម ដែលត្រូវការសំរាប់ការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះអំពីអង្គការអន្តរជាតិពាក់ព័ន្ធ ជាពិសេសអំពីស្ថានប័នហិរញ្ញវត្ថុប្រចាំតំបន់ និងសហគមន៍ម្ចាស់អំណោយអន្តរជាតិ ។

## ផ្នែកទី X: នីតិវិធី

### ប្រការទី ២៥. ពិធីសារ

១. ភាគីទាំងឡាយត្រូវសហប្រតិបត្តិការគ្នាក្នុងការតាក់តែង និងការអនុវត្តន៍យកពិធីសារទាំងឡាយចំពោះកិច្ចព្រមព្រៀងនេះ ប្រកាសប្រាប់ពីវិធានការនីតិវិធី និងគំរូស្តង់ដាដែលបានឯកភាពគ្នាសំរាប់ការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ ។

២. អត្ថបទនៃពិធីសារស្នើឡើងណាមួយត្រូវផ្តល់ជូនដំណឹងដល់ភាគីទាំងឡាយដោយលេខាធិការដ្ឋានយ៉ាងហោចណាស់ ៦០ ថ្ងៃ មុនពេលបើកសន្និសីទនៃភាគីទាំងឡាយ ។

៣. សន្និសីទនៃភាគីទាំងឡាយក្នុងការប្រជុំសមញ្ញអាចប្រកាន់យកពិធីសារ ចំពោះកិច្ចព្រមព្រៀងនេះតាមសហព័ន្ធ (Consensus) នៃភាគីទាំងអស់ចំពោះកិច្ចព្រមព្រៀងនេះ ។

៤. ពិធីសារណាមួយចំពោះកិច្ចព្រមព្រៀងនេះ ដែលប្រកាន់យកស្របទៅតាមកថាខណ្ឌពីមុខនេះត្រូវចូលជាធរមានស្របទៅតាមនីតិវិធីដូចផ្តល់ជូននៅក្នុងពិធីសារនេះ ។

### ប្រការទី ២៦. វិសោធនកម្មចំពោះកិច្ចព្រមព្រៀង

១. ភាគីណាមួយអាចលើកកំណើរសុំធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀង

២. អត្ថបទនៃវិសោធនកម្មស្នើឡើងណាមួយត្រូវជូនដំណឹងដល់ភាគីទាំងឡាយដោយលេខាធិការដ្ឋានយ៉ាងហោចណាស់ហុកសិបថ្ងៃ មុនពេលសន្និសីទនៃភាគីទាំងឡាយដែលត្រូវស្នើឡើងសំរាប់ប្រកាន់យក ។ លេខាធិការដ្ឋានក៏ត្រូវជូនដំណឹងអំពីវិសោធនកម្មស្នើឡើងនេះជូនទៅហត្ថលេខីនៃកិច្ចព្រមព្រៀង ។

៣. វិសោធនកម្មទាំងឡាយត្រូវបានប្រកាន់យកតាមសហព័ទ្ធ (consensus) នៅពេលប្រជុំសាមញ្ញនៃសន្និសីទរបស់ភាគីទាំងឡាយ ។

៤. វិសោធនកម្មទាំងឡាយទៅលើកិច្ចព្រមព្រៀងត្រូវស្ថិតក្នុងលក្ខខណ្ឌធ្វើសច្ចាប័នយល់ព្រម ឬការទទួលយកដោយភាគីទាំងឡាយចំពោះកិច្ចព្រមព្រៀងនេះ ។ អ្នកតំកល់ឯកសារត្រូវ

ផ្ញើរវិសោធនកម្មដែលប្រកាន់យកនេះជូនទៅភាគីទាំងអស់ ដើម្បីសច្ចាប័នការយល់ព្រម ឬទទួលយក។ វិសោធនកម្មត្រូវចូលជាធរមាននៅអំឡុងពេលសាមសិបថ្ងៃ ក្រោយពេលដឹកល់ទុកជាមួយអ្នកតំកល់ឯកសាររបស់ឧបករណ៍នៃសច្ចាប័នការយល់ព្រម ឬការទទួលយករបស់ភាគីទាំងអស់។

## ប្រការទី ២៧. ការប្រកាន់យក និងវិសោធនកម្មនៃឧបសម្ព័ន្ធទាំងឡាយ

១. ឧបសម្ព័ន្ធទាំងឡាយនៃកិច្ចព្រមព្រៀងនេះ និងបង្កើតបានជាផ្នែកនៃកិច្ចព្រមព្រៀង ហើយលើកលែងតែមានការបង្ហាញប្រាប់ដទៃក្រៅពីនេះ ការយោងទៅលើកិច្ចព្រមព្រៀងបង្កើតបាននៅពេលជាមួយគ្នានូវការយោងទៅរកឧបសម្ព័ន្ធទាំងឡាយចំពោះកិច្ចព្រមព្រៀងនេះ។
២. ឧបសម្ព័ន្ធទាំងឡាយ និងត្រូវប្រកាន់យកតាមសហព័ទ្ធ (Consensus) ទៅក្នុងការប្រជុំសាមញ្ញមួយនៃសន្និសីទរបស់ភាគីទាំងឡាយ។
៣. ភាគីណាមួយអាចស្នើឡើងឱ្យវិសោធនកម្មទៅលើឧបសម្ព័នមួយ
៤. វិសោធនកម្មទាំងឡាយនៅលើឧបសម្ព័ន្ធនឹងត្រូវប្រកាន់យកតាមសហព័ន្ធនៅក្នុងការប្រជុំសាមញ្ញមួយនៃសន្និសីទរបស់ភាគីទាំងឡាយ។
៥. ឧបសម្ព័ន្ធទាំងឡាយនៃកិច្ចព្រមព្រៀង និងវិសោធនកម្មទាំងឡាយទៅលើឧបសម្ព័ន្ធត្រូវស្ថិតនៅក្នុងខ័ណ្ឌ ផ្ញើសច្ចាប័ន ការយល់ព្រម ឬការទទួលយក។ អ្នកតំកល់ឯកសារត្រូវបញ្ជូននូវឧបសម្ព័ន្ធដែលប្រកាន់យកនេះ ឬវិសោធនកម្មនៅលើឧបសម្ព័ន្ធមួយដែលប្រកាន់យកនេះទៅកាន់ភាគីទាំងអស់ ដើម្បីទទួលសច្ចាប័ន ការយល់ព្រម ឬការទទួលយក។ឧបសម្ព័ន្ធ ឬវិសោធនកម្មនៅលើឧបសម្ព័ន្ធមួយត្រូវចូលជាធរមាននៅថ្ងៃទីសាមសិបក្រោយពេលតំកល់ទុកជាមួយអ្នកតំកល់ឯកសាររបស់ឧបករណ៍នៃសច្ចាប័ន ការយល់ព្រមរឺការទទួលយករបស់ភាគីទាំងអស់។

## ប្រការទី ២៨. ក្រិត្យក្រមនៃនិតិវិធី និងក្រិត្យក្រមហិរញ្ញវត្ថុ

សន្និសីទទី១ របស់ភាគីទាំងឡាយត្រូវប្រកាន់យកតាមសហព័ន្ធនូវក្រិត្យក្រមនៃនីតិវិធីសំរាប់ខ្លួន និងផ្ទាល់ និងក្រិត្យក្រមហិរញ្ញវត្ថុសំរាប់មូលនិធិគ្រប់គ្រងគ្រោះមហន្តរាយ និងជួយសង្គ្រោះគ្រោះអាសន្នអាស៊ានដើម្បីកំណត់ ជាពិសេសការចូលរួមហិរញ្ញវត្ថុសំរាប់ភាគីទាំងឡាយនៃកិច្ចព្រមព្រៀងនេះ។

## ប្រការទី ២៩. របាយការណ៍

ភាគីទាំងឡាយត្រូវបញ្ជូនទៅអោយលេខាធិការដ្ឋាននូវរបាយការណ៍ទាំងឡាយស្តីពីវិធានការប្រកាន់យកសំរាប់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះទៅតាមទំរង់មួយ និងនៅក្នុងថេរៈវេលាមួយកំណត់ដោយសន្និសីទនៃភាគីទាំងឡាយ។

## ប្រការទី ៣០. ភាពទំនាក់ទំនងជាមួយឧបករណ៍ផ្សេងទៀត

បទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះមិនត្រូវប៉ះពាល់ទៅលើសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីណាមួយទាក់ទងទៅនឹងសន្ធិសញ្ញា កតិ្តការសញ្ញា ឬឧបករណ៍ណាមួយ ដែលខ្លួនជាភាគីនោះឡើយ។

## ប្រការទី ៣១. ដំណោះស្រាយជំលោះ

រាល់ជំលោះណាមួយរវាងភាគីទាំងឡាយនៅពេលបកស្រាយ ឬអនុវត្តណាមួយ ឬគោរពតាមចំពោះកិច្ចព្រមព្រៀងនេះ ឬតាមពិធីសារណាមួយនោះនឹងត្រូវបានដោះស្រាយប្រកបដោយមិត្តភាពតាមរយៈការពិគ្រោះយោបល់គ្នា ឬចរចារគ្នា។

# ផ្នែកទី XI: អវសានបទ

## ប្រការទី ៣២. សច្ចាប័ន ការទទួលយក ការយល់ព្រម និងការទទួលបាន

កិច្ចព្រមព្រៀងនេះត្រូវទទួលការធ្វើសច្ចាប័ន ការទទួលយក និងការយល់ព្រម រឺការទទួលដឹងដោយរដ្ឋជាសមាជិក។ ឧបករណ៍នៃសច្ចាប័ន ការទទួលយក ការយល់ព្រម ឬការទទួលដឹងត្រូវតំកល់ទុកជាមួយអ្នកតំកល់ឯកសារ។

## ប្រការទី ៣៣. ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទីហុកសិប ក្រោយពេលតំកល់ទុកនូវលិខិតឧបករណ៍ទី១០ នៃសច្ចាប័ន ការទទួលយក ការយល់ព្រម រឺការទទួលដឹង។

## ប្រការទី ៣៤. ការបំរុង

លើកលែងតែមានការបង្ហាញដោយកិច្ចព្រមព្រៀងនេះពុំមានការបំរុងទុកណាអាចត្រូវបានធ្វើឡើងចំពោះកិច្ចព្រមព្រៀងនេះឡើង ។

## ប្រការទី ៣៥. អ្នកតំកល់ឯកសារ

កិច្ចព្រមព្រៀងនេះត្រូវតំកល់ទុកជាមួយលេខាធិការរបស់អាស៊ានដែល និងផ្តល់ជូនភ្លាមៗដល់រដ្ឋជាសមាជិកនូវឯកសារចំលងមានការញ្ជាក់ និងឯកសារផ្សេងៗរបស់ពិធីសារ ឧបសម្ព័ន្ធ និងវិសោធនកម្ម ។

## ប្រការទី ៣៦. អត្ថបទជាក់ស្តែង

កិច្ចព្រមព្រៀងនេះត្រូវសរសេរជាភាសាអង់គ្លេស និងត្រូវជាអត្ថបទជាក់ស្តែង ។

ជាសក្ខីភាព នៃឯកសារចុះហត្ថលេខាខាងក្រោមកិច្ចព្រមព្រៀង ត្រូវបានការអនុញ្ញាតអោយចុះហត្ថលេខា ដោយរដ្ឋាភិបាលរៀងៗខ្លួន ។

ធ្វើនៅទីក្រុងវៀងចន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នាថ្ងៃទីម្ភៃប្រាំមួយ ខែ កក្កដា ឆ្នាំពីរពាន់ប្រាំជាឯកសារតែមួយគត់សរសេរជាភាសាអង់គ្លេស ។

**ជ. ប្រ៊ុយណេ ដារូសសាឡឹម**

**ម៉ូហាម៉េដ បុលឃីយ៉ា**
**រដ្ឋមន្ត្រីក្រសួងការបរទេស**

**ជ. ព្រះរាជាណាចក្រកម្ពុជា**

**ហោ ណាំហុង**
**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ជ. សាធារណរដ្ឋឥណ្ឌូនេស៊ី

**ន.ហាស់សានវីរជុដា**

រដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ. សាធារណរដ្ឋប្រជាធិតេយ្យ ប្រជាមានិត្យឡាវ

**ស៊ុំសាវ៉ាត់ ឡេងសាវ៉ាដ**

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ.ម៉ាឡេស៊ី

**ដាតុ សេរីស៊ីយ៉េដ ហាមិដអាល់បា**

រដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ. សហភាពមីយ៉ាន់ម៉ារ

**ណីយ៉ាក វិន**

រដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ. សាធារណរដ្ឋហ្វីលីពីន



**អាល់ប៊ែរតូ ជ.រ៉ូមូឡូ**
រដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ. សាធារណរដ្ឋសិង្ហបុរី



**ហ្សិក យ៉ូ-ប៊ុនយ៉េន**
រដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ. ព្រះរាជាណាចក្រថៃឡង់



**កាន់តាធី សុផាម៉ុងខុន**
រដ្ឋមន្ត្រីក្រសួងការបរទេស

---

ជ. សាធារណរដ្ឋសង្គមនិយមវៀតណាម



**ង្វៀង ឌីញៀន**
រដ្ឋមន្ត្រីក្រសួងការបរទេស

---

ឯកសារបកប្រែក្រៅផ្លូវការដោយ ឯកឧត្តម ពៅ សាមី អគ្គលេខាធិការ គជគម

# ឧបសម្ព័ន្ធ

## លក្ខខណ្ឌការងាររបស់មជ្ឈមណ្ឌលសំរបសំរួលអាស៊ានសំរាប់ជំនួយមនុស្សធម៌ (មជ្ឈមណ្ឌល AHA)

មជ្ឈមណ្ឌលសំរបសំរួលអាស៊ាន សំរាប់ជំនួយមនុស្សធម៌ក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ (មជ្ឈមណ្ឌល AHA) នឹងត្រូវរៀបចំឡើង ដើម្បីគោរពបំណងបង្កភាពងាយស្រួលដល់កិច្ចសហប្រតិបត្តិការ និងសំរបសំរួលក្នុងចំណោមភាគីទាំងឡាយ និងព្រមជាមួយអង្គការសហប្រជាជាតិ អង្គការអន្តរជាតិពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តដល់កិច្ចសហការគ្នា។ ក្នុងករណីនេះមជ្ឈមណ្ឌលត្រូវអនុវត្តនីមុខងារដូចតទៅ :

(I). ទទួល និងគាំទ្រដល់ទិន្នន័យដូចបានវិភាគ និងផ្តល់អនុសាសន៍អំពីកំរិតគ្រោះភ័យដោយមន្ត្រីទទួលបន្ទុកជាតិ (ប្រការ ៥.៤)

(II). ដោយផ្អែកលើមូលដ្ឋានព័ត៌មានបែបនេះត្រូវផ្ញើជូនភាគីនីមួយៗ តាមរយៈមន្ត្រីទទួលបន្ទុកថ្នាក់ជាតិរបស់ខ្លួននូវទិន្នន័យដែលបានវិភាគ និងកំរិតគ្រោះភ័យដែលកើតចេញពីមុខសញ្ញាគ្រោះថ្នាក់រកឃើញ (ប្រការ ៥.៤)

(III). បើយល់ឃើញថាសមស្របត្រូវធ្វើការវិភាគទៅលើសកម្មភាពទាំងឡាយ ដែលអាចស្មើឡើងនៅកំរិតថ្នាក់តំបន់ (ប្រការ ៥.៤)

(IV). ទទួលពត៌មានទាក់ទងនឹងធនធាន ដែលអាចប្រើប្រាស់បានសំរាប់ការរៀបចំបំរុងថ្នាក់តំបន់ដើម្បីជួយសង្គ្រោះគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ (ប្រការ ៨.៤)

(V). បង្កភាពងាយស្រួលដល់ការរៀបចំការថែទាំ និងការពិនិត្យឡើងវិញតាមកាលវេលារបស់ការរៀបចំរុងថ្នាក់តំបន់សំរាប់ការជួយសង្គ្រោះគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់ (ប្រការ ៨.៦)

(VI). បង្កភាពងាយស្រួលដល់ការពិនិត្យឡើងវិញតាមកាលវេលារបស់នីតិវិធីប្រតិបត្តិការតាមគំរូស្តង់ដា (ប្រការ ៨.៦)

(VII). ទទួលទិន្ន័យស្តីពីសំភារៈបរិក្ខា និងសមត្ថភាពរំពឹងទុកដែលអាចប្រើប្រាស់បានសំរាប់ការរៀបចំបំរុងថ្នាក់តំបន់ដើម្បីជួយសង្គ្រោះមហន្តរាយ និងឆ្លើយតបសង្គ្រោះបន្ទាន់ដូចបានជូនដំណឹងដោយភាគីនីមួយៗព្រមទាំងស្ថានភាពបច្ចុប្បន្ន និងផ្ញើចែករំលែកទិន្នន័យស្តីពីសំភារៈបរិក្ខា និងសមត្ថភាពទាំងនោះ (ប្រការ ៩.១)

(VIII). គាំទ្របញ្ជាក់ពីស្ថានភាពបច្ចុប្បន្ន និងផ្ញើចែករំលែកទិន្នន័យស្តីពីសំភារៈបរិក្ខា និងសមត្ថភាពដែលរំពឹងទុកព្រមទាំងប្រាស្រ័យទាក់ទងគ្នាជាមួយភាគីទាំងឡាយសំរាប់ការប្រើប្រាស់របស់គេ (ប្រការ ៩.២)

(IX). ទទួលព័ត៌មានអំពីវិធានការ ដែលប្រកាន់យកដោយភាគីទាំងឡាយដើម្បីកៀរគរ

បរិក្ខារ មូលដ្ឋាន សំភារៈគ្រឿងសំភារៈ ធនធានមនុស្ស និងហិរញ្ញវត្ថុដែលត្រូវការសំរាប់ឆ្លើយតបចំពោះគ្រោះមហន្តរាយ ( ប្រការ ១០.២)

(X). បង្កភាពងាយស្រួលដល់ការឆ្លើយតបសង្គ្រោះបន្ទាន់រួមគ្នា ( ប្រការ ១១)

(XI). បីយល់ឃើញថាសមស្របត្រូវបង្កភាពងាយស្រួលដល់ដំណើរការលើកលែងពន្ធ និងមូលដ្ឋានសំភារៈ ស្របទៅតាមបទប្បញ្ញត្តិនៃការជួយគ្នា ( ប្រការ ១៤ C)

(XII). បើយល់ឃើញថាអនុវត្តន៍បាន និងសមស្របត្រូវបង្កភាពងាយស្រួលដល់ដំណើរការឆ្លងកាត់នៃបុគ្គលិក បរិក្ខារ មូលដ្ឋានសំភារៈ និងគ្រឿងសំភារៈផ្សេងៗ ស្របទៅតាមបទប្បញ្ញត្តិនៃការជួយគ្នា ( ប្រការ ១៨.២)

(XIII). បង្កភាពងាយស្រួលដល់សកម្មភាពកិច្ចសហប្រត្តិបត្តិការបច្ចេកទេស ( ប្រការ ១៨.២)

(XIV). បង្កភាពងាយស្រួលដល់សកម្មភាពសំរាប់ការសិក្សាស្រាវជ្រាវវិទ្យាសាស្រ្តបច្ចេកទេស ( ប្រការ ១៩.២)

(XV). ទទួលពីភាគីនីមួយៗនូវព័ត៌មានអំពីមន្រ្តីទទួលបន្ទុកថ្នាក់ជាតិ និងអាជ្ញាធរមានសមត្ថកិច្ចដែលបានចាត់តាំង ព្រមទាំងការផ្លាស់ប្តូរជាបន្ទាប់ណាមួយក្នុងការចាត់តាំងរបស់គេ ( ប្រការ ២២) និង

(XVI). ផ្តល់ដោយទៀងទាត់និងទាន់ពេលវេលាជូនទៅភាគីទាំងឡាយ ហើយបើចាំបាច់ជូនទៅអង្គការអន្តរជាតិពាក់ព័ន្ធនូវព័ត៌មានយោងនៅកថាខណ្ឌ (XV) ខាងលើនេះ ( ប្រការ ២២.៣)

ស្ថាប័នផ្តល់រូបភាព :

ភ្លើងឆេះនៅតាមជនបទ ក្នុងខេត្តកំពង់អាយឺ (នាយកដ្ឋានជួយសង្គ្រោះ និងពនល្លត់អគ្គិភ័យ ប្រ៊ុយណេ ដារូសសាឡឹម)

ស្ត្រីម្នាក់រងគ្រោះដោយរលកយក្សស៊ូណាមិ ក្នុងខេត្តអាឆេះ សាធារណរដ្ឋឥណ្ឌូនេស៊ី

ភ្នំភ្លើងមើរ៉ាពីផ្ទះ (នាយកដ្ឋានសុខុមាលភាពសង្គម សាធារណរដ្ឋឥណ្ឌូនេស៊ី)

ទឹកជំនន់ឆ្នាំ២០០២ (ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយជាតិ សាធារណរដ្ឋប្រជាធិតេយ្យ ប្រជាមានិតឡាវ)

គ្រោះថ្នាក់តាមសមុទ្រ (ទីប្រឹក្សាសម្របសម្រួលគ្រោះមហន្តរាយជាតិ សាធារណរដ្ឋហ្វីលីពីន)

រុករក និងជួយសង្គ្រោះ (កងកំលាំងការពារស៊ីវិល សាធារណរដ្ឋសិង្ហបូរី)

ភ្លើងឆេះជាយក្រុង (កងកំលាំងការពារស៊ីវិល សាធារណរដ្ឋសឹង្ហបូរី)

រថយន្តត្រូវបានបំផ្លាញដោយរលកយក្សស៊ូណាមិ (មន្ទីរគ្រប់គ្រងភ្លើងឆេះព្រៃ ព្រះរាជាណាចក្រថៃឡង់)

ទឹកជំនន់ (នាយកដ្ឋានសម្រាល និងការពារគ្រោះមហន្តរាយ ព្រះរាជាណាចក្រថៃឡង់)

Printed by **Cam-Digital Publishing.** Tel: 017 70 70 70



សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍

គេហទំព័រ www.asean.org

ទស្សនៈតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ